Seattle Office of Labor Standards

# Domestic Workers Ordinance

## ព័ត៌មានអំពីគំរូសេចក្តីជូនដំណឹងស្តីពីសិទ្ធិ និងប្រាក់ឈ្នួលឆ្នាំ

អង្គភាពដែលជួល ឬបង់ប្រាក់ជួលសេវាកម្មពីកម្មករ/និយោជិតក្នុងស្រុកដែលធានាដោយ Domestic Workers Ordinance (បទប្បញ្ញត្តិស្តីពីកម្មករ/និយោជិតក្នុងស្រុក) ត្រូវបានលើកទឹកចិត្តឱ្យចែករំលែកគំរូសេចក្តីជូនដំណឹងនេះទៅកម្មករ/និយោជិតរបស់ខ្លួន ជាភាសាដែលពួកគេងាយយល់បំផុត។ សេចក្តីជូនដំណឹងនេះមិនមែនជាដំបូន្មានផ្លូវច្បាប់ ហើយក៏មិនបង្កើតឱ្យមានកិច្ចសន្យាណាមួយជាមួយទីក្រុង Seattle ឡើយ។

កាលបរិច្ឆេទនៃសេចក្តីជូនដំណឹង ____/____/____ ឈ្មោះកម្មករ/និយោជិត ______________________

ឈ្មោះអង្គភាពជួល ______________________ លេខទូរសព្ទ ឬអ៊ីមែលអង្គភាពជួល ______________________

អាសយដ្ឋានអង្គភាពជួល ______________________

## សិទ្ធិទទួលបានប្រាក់កម្រៃអប្បបរមា

អ្នកមានសិទ្ធិរកបានយ៉ាងតិចនូវប្រាក់ឈ្នួលអប្បបរមារបស់ទីក្រុង Seattle។ ប្រាក់ឈ្នួលជាម៉ោងរបស់អ្នកគឺ៖ $____________ / ម៉ោង។

អ្នកនឹងទទួលបានប្រាក់ទូទាត់នៅ៖ ______________________
(ឧ. នៅចុងម៉ោងនៃថ្ងៃធ្វើការនីមួយៗ រៀងរាល់ថ្ងៃសុក្រ រៀងរាល់ 2 សប្តាហ៍នៅថ្ងៃអង្គារ។ល។)

### លក្ខខណ្ឌទទួលបានប្រាក់ថែមម៉ោង៖ គូសចំណុចដែលត្រឹមត្រូវ

- ☐ អ្នកមិនមានសិទ្ធិទទួលបានប្រាក់ថែមម៉ោងទេ។
- ☒ អ្នកគឺជានិយោជិតដែល "មានសិទ្ធិទទួលបានប្រាក់ថែមម៉ោង" ដែលមានន័យថា គេត្រូវទូទាត់ជូនអ្នកក្នុងអត្រា 1.5 ដងនៃប្រាក់ឈ្នួលធម្មតា សម្រាប់ម៉ោងដែលបានធ្វើការលើសពី 40 ម៉ោងក្នុងសប្តាហ៍ធ្វើការ។

### ប្រាក់ឈ្នួលអប្បបរមាជាម៉ោង

ដើម្បីរកមើលប្រាក់ឈ្នួលអប្បបរមាបច្ចុប្បន្ន របស់ទីក្រុង Seattle និងស្វែងយល់បន្ថែម សូមចូលមើល៖ seattle.gov/domestic-workers ឬស្កេនកូដ QR នេះ

** ប្រសិនបើអ្នកគឺជានិយោជិត នោះនិយោជករបស់អ្នកត្រូវតែផ្តល់ព័ត៌មានអំពីគោលការណ៍ស្តីពីប្រាក់ធីបរបស់ខ្លួន។

គូសធីក បើបានភ្ជាប់ ☐

## សិទ្ធិទទួលបានការសម្រាកក្នុងម៉ោងធ្វើការ

រៀងរាល់ 4 ម៉ោងដែលអ្នកធ្វើការឱ្យអង្គភាពជួលមួយ អ្នកមានសិទ្ធិទទួលបានការសម្រាក 10 នាទីដោយគ្មានការរំខាន និងមានប្រាក់ឈ្នួលនៅចុងម៉ោងទី 3 នៃការងាររបស់អ្នក។

### ការសម្រាកក្នុងម៉ោងធ្វើការ៖ គូសធីកចំណុចដែលត្រឹមត្រូវ

អ្នកនឹងអាចសម្រាកក្នុងម៉ោងធ្វើការដោយគ្មានការរំខាន និងមានប្រាក់ឈ្នួល។

អ្នកនឹងអាចសម្រាកក្នុងម៉ោងធ្វើការដោយបន្តស្ថិតនៅកន្លែងធ្វើការ និងតម្រូវឱ្យត្រឡប់មកធ្វើការវិញនៅពេលចាំបាច់។ ប្រសិនបើអ្នកទទួលខុសត្រូវលើសុខភាព និងសុវត្ថិភាពរបស់នរណាម្នាក់ក្រោមការថែទាំរបស់អ្នក នោះអ្នកអាចនឹងខកខានការសម្រាកដោយសារតែភារកិច្ចរបស់អ្នក។ ក្នុងកាលៈទេសៈទាំងនេះ អ្នកនឹងទទួលបានប្រាក់ឈ្នួល 10 នាទីបន្ថែមឬ $__________ សម្រាប់ការខកខានសម្រាកក្នុងម៉ោងធ្វើការម្តងៗ។

ភារកិច្ចរបស់អ្នកមិនអាចឱ្យអ្នកសម្រាកក្នុងម៉ោងធ្វើការដោយគ្មានការរំខាន ដោយមិនបង្កគ្រោះថ្នាក់ដល់សុខភាព និងសុវត្ថិភាពរបស់មនុស្សដែលស្ថិតក្រោមការថែទាំរបស់អ្នកឡើយ។ អ្នកនឹងទទួលបានប្រាក់ឈ្នួល 10 នាទីបន្ថែម ឬ $____________ រៀងរាល់ 4 ម៉ោងធ្វើការ។

### លក្ខខណ្ឌតម្រូវនៃការសម្រាកក្នុងម៉ោងធ្វើការ៖

- ការសម្រាកនេះត្រូវតែអាចឱ្យអ្នកសម្រាក និងធ្វើការជ្រើសរើសផ្ទាល់ខ្លួនផ្សេងទៀតអំពីរបៀបដែលអ្នកចំណាយពេលរបស់អ្នក។
- អ្នកអាចត្រូវបានស្នើឱ្យបន្តស្ថិតនៅ កន្លែងធ្វើការនៅពេលចាំបាច់ ហើយត្រឡប់មកធ្វើការវិញ ប៉ុន្តែបើគ្មានការចាំបាច់ អ្នកអាចសម្រាកពីការងារបាន។
- ប្រសិនបើការសម្រាករបស់អ្នកត្រូវបានរំខានដោយនិយោជកឬការងាររបស់អ្នក នោះការសម្រាកត្រូវចាប់ផ្តើមឡើងវិញ រហូតដល់អ្នកសម្រាកបាន 10 នាទីឥតដាច់។

*ចំណាំ៖ កម្មករ/និយោជិតដែលជួលដោយផ្ទាល់ពីសំណាក់អង្គភាពជួលអាចមានសិទ្ធិទទួលបានស្តង់ដារការងារបន្ថែមរបស់រដ្ឋ និងតំបន់ រួមទាំងម៉ោងឈប់សម្រាកដើម្បីរក្សាសុវត្ថិភាព និងឈឺដោយមានប្រាក់ឈ្នួល។ មើលព័ត៌មានបន្ថែមអំពីសិទ្ធិរបស់និយោជិតនៅ www.seattle.gov/laborstandards។

## សិទ្ធិទទួលបានពេលញ៉ាំអាហារ

រៀងរាល់ 5 ម៉ោងដែលអ្នកធ្វើការឱ្យអង្គភាពជួលមួយ អ្នកមានសិទ្ធិទទួលបានពេលញ៉ាំអាហារ 30 នាទីដោយគ្មានការរំខាននៅចុងម៉ោងទី 5។

### ពេលញ៉ាំអាហារ៖ គូសធីកចំណុចដែលត្រឹមត្រូវ

ក្នុងអំឡុងពេលញ៉ាំអាហារ អ្នកនឹងសម្រាកពីការងាររបស់អ្នកទាំងស្រុង។ អ្នកនឹងទទួលបានពេលញ៉ាំអាហារដោយគ្មានប្រាក់ឈ្នួល។ អ្នកអាចលះបង់ពេលញ៉ាំអាហារដោយគ្មានប្រាក់ឈ្នួល។ មើលលក្ខខណ្ឌតម្រូវអំពីការបោះបង់សិទ្ធិក្នុងប្រអប់ចំហៀង។

ក្នុងអំឡុងពេលញ៉ាំអាហារ អ្នកត្រូវបន្តស្ថិតនៅកន្លែងធ្វើការ និងត្រឡប់មកធ្វើការវិញនៅពេលចាំបាច់ ប៉ុន្តែបើគ្មានការចាំបាច់អ្នកអាចសម្រាកពីការងារបាន។អ្នកនឹងទទួលបានពេលញ៉ាំអាហារដោយមានប្រាក់ឈ្នួល។ អ្នកមិនអាចលះបង់ពេលញ៉ាំអាហារដែលមានប្រាក់ឈ្នួលនេះទេ។

អ្នកទទួលខុសត្រូវលើសុខភាពនិងសុវត្ថិភាពរបស់សមាជិកគ្រួសារ ប៉ុន្តែអ្នកគួរតែអាចទទួលបានពេលញ៉ាំអាហារដោយមានប្រាក់ឈ្នួល។ នៅថ្ងៃដែលអ្នកខកខានពេលញ៉ាំអាហារដោយសារតែភារកិច្ច អ្នកត្រូវតែទទួលបានប្រាក់ឈ្នួលបន្ថែម 30 នាទី ឬ $______________ រៀងរាល់ពេលខកខានញ៉ាំអាហារម្តងៗ។

Yភារកិច្ចរបស់អ្នកមិនអាចឱ្យអ្នកមានពេលញ៉ាំអាហារដោយគ្មានការរំខាន ដោយមិនបង្កគ្រោះថ្នាក់ដល់សុខភាព និងសុវត្ថិភាពរបស់មនុស្សដែលស្ថិតក្រោមការថែទាំរបស់អ្នកឡើយ។ អ្នកនឹងទទួលបានប្រាក់ឈ្នួល 30 នាទីបន្ថែម ឬ $____________ រៀងរាល់ 5 ម៉ោងធ្វើការ។

### លក្ខខណ្ឌតម្រូវនៃពេលញ៉ាំអាហារ៖

- ពេលញ៉ាំអាហារនេះត្រូវតែអាចឱ្យអ្នកសម្រាក និងធ្វើការជ្រើសរើសផ្ទាល់ខ្លួនផ្សេងទៀតអំពីរបៀបដែលអ្នកចំណាយពេលរបស់អ្នក។
- ប្រសិនបើពេលញ៉ាំអាហាររបស់អ្នកត្រូវបានរំខានដោយនិយោជកឬការងាររបស់អ្នក នោះពេលញ៉ាំអាហារចាប់ផ្តើមឡើងវិញរហូតដល់ អ្នកអាចសម្រាកបាន 30 នាទីឥតដាច់។

### ឬថ្ងៃឈប់សម្រាក?

- ការលះបង់សិទ្ធិនេះត្រូវតែធ្វើឡើងដោយស្ម័គ្រចិត្តនិងផ្តល់ផលប្រយោជន៍ដល់កម្មករ/និយោជិត។
- អ្នកត្រូវតែទទួលបានដំណឹងអំពីសិទ្ធិដែលអ្នកកំពុងលះបង់ និងផលវិបាកនៃការលះបង់សិទ្ធិ។
- ការលះបង់សិទ្ធិរបស់អ្នកគួរតែបញ្ជាក់កាលបរិច្ឆេទប្រសិទ្ធភាពនៃការលះបង់សិទ្ធិ។
- អ្នកមានសិទ្ធិរំលាយការលះបង់សិទ្ធិនេះបានគ្រប់ពេល។

## សិទ្ធិទទួលបានថ្ងៃឈប់សម្រាក

ប្រសិនបើអ្នកធ្វើការ 6 ថ្ងៃជាប់គ្នា ហើយរស់នៅឬធ្វើការនៅកន្លែងធ្វើការ អ្នកមានសិទ្ធិទទួលបានពេលសម្រាក 24 ម៉ោងដោយគ្មានប្រាក់ឈ្នួល។

- បើមានការងារក្នុងទំហំណាក៏ដោយក្នុងរយៈពេល 24 ម៉ោងនេះនឹងចាត់ទុកជាថ្ងៃធ្វើការមួយថ្ងៃ។
- ក្នុងអំឡុងពេលសម្រាក24ម៉ោងនេះអ្នកត្រូវតែសម្រាកពីការងារទាំងស្រុងមិនតម្រូវឱ្យបន្តស្ថិតនៅកន្លែងធ្វើការ ឬត្រឡប់ទៅធ្វើការវិញប្រសិនបើចាំបាច់ឡើយ។
- អ្នកអាចលះបង់សិទ្ធិទទួលបានថ្ងៃសម្រាកបាន។ មើលលក្ខខណ្ឌតម្រូវអំពីការបោះបង់សិទ្ធិក្នុងប្រអប់ចំហៀង។

## សិទ្ធិរក្សាទុកឯកសារផ្ទាល់ខ្លួន

អ្នកមានសិទ្ធិរក្សាទុកឯកសារដើម និងវត្ថុផ្ទាល់ខ្លួនរបស់អ្នកបាន។

## ការសងសឹកត្រូវបានហាមឃាត់

អ្នកមានសិទ្ធិរួចផុតពីការសងសឹក។ វាជាទង្វើខុសច្បាប់ បើអង្គភាពជួលណាមួយចាត់វិធានការសងសឹក (ឧ. បញ្ឈប់ការងារ ទម្លាក់តំណែង និងគំរាមរាយការណ៍អំពីស្ថានភាពអន្តោប្រវេសន៍) ទៅលើអ្នក ដោយសារអ្នកបានអនុវត្តសិទ្ធិដែលការពារដោយ Seattle Labor Standards (ការិយាល័យស្តង់ដារពលកម្មនៃទីក្រុង Seattle)។

### មានសំណួរ ឬបណ្តឹងតវ៉ាឬ?

ដើម្បីសួរសំណួរ ឬដាក់បណ្តឹងតវ៉ា សូមទាក់ទងទៅ៖ **Seattle Office of Labor Standards (ការិយាល័យស្តង់ដារពលកម្មនៃទីក្រុង Seattle) តាមរយៈលេខ (206) 256-5297** ឬចូលទៅកាន់ www.seattle.gov/laborstandards។

សេវាកម្មរបស់ពួកគេគឺឥតគិតថ្លៃ។
ពួកគេនឹងផ្តល់សេវាបកប្រែភាសាផ្ទាល់មាត់ដោយឥតគិតថ្លៃ។
ពួកគេនឹងមិនសួរអំពីស្ថានភាពអន្តោប្រវេសន៍របស់អ្នកទេ។

### ការការពារសិទ្ធិពលរដ្ឋ

កម្មករ/និយោជិតក្នុងស្រុកក៏មានសិទ្ធិរួចផុតពីការបៀតបៀនផ្លូវភេទ ការសងសឹក និងការរើសអើងតាម Seattle's Fair Employment Practices Law (ច្បាប់របស់ទីក្រុង Seattle ស្តីពីការអនុវត្តដោយយុត្តិធម៌ចំពោះការងារ) ផងដែរ។

សម្រាប់ព័ត៌មានបន្ថែមអំពីសិទ្ធិនេះ សូមទាក់ទងទៅ៖ **Seattle Office for Civil Rights (ការិយាល័យទទួលបន្ទុកផ្នែកសិទ្ធិពលរដ្ឋនៃទីក្រុង Seattle) តាមរយៈលេខ (206) 684-4500** ឬចូលទៅកាន់ www.seattle.gov/civilrights។